ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

រាប់បញ្ចូលច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម

ឆ្នាំ២០១៤

# LAW

# ON

# ADMINISTRATION OF FACTORY AND HANDICRAFT

**Including provision of Amendment Law to the Law on the Administration of Factory and Handicraft**

**Year 2014**

ចងក្រងដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១.-ថ្មី

ច្បាប់នេះមានវិសាលភាពចំពោះរោងចក្រ និងសិប្បកម្មទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមិនប៉ះពាល់ដល់សមត្ថកិច្ចរបស់ក្រសួងស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធ ។

### មាត្រា២.-

រោងចក្រ និងសិប្បកម្មដែលមានចែងក្នុងច្បាប់នេះ សំដៅលើអគារ ទីកន្លែង ឬ យានយន្តសម្រាប់ផលិត បំប្លែងវត្ថុធាតុដើម ឬផលិតផលពាក់កណ្តាលសម្រេចឱ្យទៅជាផលិតផលថ្មី ឬ/និង សម្រាប់ធ្វើសកម្មភាពផ្សេងទៀត ដែលមានជាអាទិ៍ ផ្គុំ ដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ច្រកបំពេញ ថែទាំ រក្សាទុក កែលម្អ ដើម្បីបម្រើសេចក្តីត្រូវការទីផ្សារ ។

### មាត្រា៣.-ថ្មី

រោងចក្រ និងសិប្បកម្មដែលស្ថិតក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានដូចខាងក្រោម៖

១-ផ្នែកស្បៀង ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់

២-ផ្នែកវាយនភ័ណ្ឌ សម្លៀកបំពាក់ និងផលិតផលអំពីស្បែក

៣-ផ្នែកផលិតផលក្រដាស

៤-ផ្នែកគីមី ផលិតផលពីកៅស៊ូ ផ្លាស្ទិច លើកលែងតែឧស្សាហកម្មប្រេងកាត និងឧស្ម័ន

៥-ផ្នែកផលិតផលពីរ៉ែអលោហៈ

៦-ផ្នែកលោហៈមូលដ្ឋាន

៧-ផ្នែកកែច្នៃលោហៈ ម៉ាស៊ីន និងគ្រឿងបរិក្ខារ

៨-ផ្នែកផ្សេងទៀតមានជាអាទិ៍ ផលិតគ្រឿងអលង្ការ រតនភ័ណ្ឌ និងលម្អឧបករណ៍សិល្បៈ កីឡា ក្មេងលេង និងសម្ភារៈការិយាល័យ ។

## ជំពូកទី ២
## ការបង្កើត និងកិច្ចដំណើរការ
## ផ្នែកទី
## រោងចក្រ

### មាត្រា៤.-ថ្មី

ការបង្កើតរោងចក្រដែលមានចែងក្នុងមាត្រា ៣ ថ្មី ត្រូវមានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានយោបល់ឯកភាពពីក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ។ ការបង្កើតរោងចក្រផ្តោតសំខាន់ទៅលើះ

- ការរៀបចំទីកន្លែង ឬ/និង ការសាងសង់អគារ សម្រាប់ដំណើរការរោងចក្រ
- ការសាងសង់អគារ សម្រាប់បំពាក់ម៉ាស៊ីនដើម្បីដំណើរការរោងចក្រ
- ការបំពាក់ម៉ាស៊ីនក្នុងអគារ ទីកន្លែង ឬយាន្ត សម្រាប់ដំណើរការរោងចក្រ
- វត្ថុធាតុដើមសម្រាប់ដំណើរការរោងចក្រ។

### មាត្រា៥.-

ម្ចាស់រោងចក្រត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ ម្ចាស់រោងចក្រអាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

### មាត្រា៦.-

ការត្រួតពិនិត្យគុណភាព ការកំណត់ស្តង់ដា ការចុះបញ្ជី និងសញ្ញាបញ្ជាក់ផលិតផលត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

### មាត្រា៧.-ថ្មី

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវផ្តល់លិខិតបញ្ជាក់ផ្សេងៗពាក់ព័ន្ធនឹងផលិតកម្មតាមការស្នើសុំរបស់ម្ចាស់រោងចក្រ បើពិនិត្យឃើញថាជាការចាំបាច់ ។

### មាត្រា៨.-ថ្មី

ក្រសួងឧស្សាហកម្ម និងសិប្បកម្មត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកសុំបង្កើតរោងចក្រក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ យ៉ាងយូរនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ក្នុងករណីមិនយល់ព្រមលើពាក្យសុំបង្កើតរោងចក្រ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវពន្យល់ហេតុផលលើការសម្រេចរបស់ខ្លួនឱ្យបានច្បាស់លាស់ ។

**មាត្រា៩.-ថ្មី**

មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានមុនរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងតិច។

**មាត្រា១០.-**

ក្នុងការបង្កើតនិងកិច្ចដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវប្រើប្រាស់វិស្វករ ឬ អ្នកបច្ចេកទេស ដែលមានសញ្ជាតិខ្មែរជាអាទិភាព ។ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់វិស្វករ អ្នកបច្ចេកទេសបរទេស ត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា១១.-ថ្មី**

ក្នុងការពង្រីកឬការបង្កើតសាខា ឬការផ្លាស់ប្តូរទីតាំងរោងចក្រត្រូវតែមានលិខិតអនុញ្ញាត ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា១២.-**

ការពង្រីករោងចក្រ គឺជាការបង្កើនសមត្ថភាពផលិតកម្មលើសពី ២០ (ម្ភៃ) ភាគរយ នៃសមត្ថភាពដើម ដោយៈ

១- ការបង្កើនចំនួនម៉ាស៊ីន ឬការផ្លាស់ប្តូរម៉ាស៊ីន

២- ការរុះរើដើម្បីរៀបចំ ឬការពង្រីក ឬការសាងសង់អគារ

៣- ការផ្លាស់ប្តូរមុខផលិតផល ឬ បន្ថែមមុខផលិតផល

៤- ការពង្រីកបរិវេណរោងចក្រ

ការបង្កើតសាខារោងចក្រ គឺជាការបង្កើតមូលដ្ឋានផលិតកម្មថ្មី ដែលធ្វើផលិតកម្មបម្រើឱ្យ រោងចក្រដើម ។

ការផ្លាស់ប្តូរទីតាំង គឺការផ្លាស់ប្តូររោងចក្រទីតាំងចាស់ទៅទីតាំងថ្មី ។

**មាត្រា១៣.-ថ្មី**

ក្នុងករណីប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មីត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់ រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធិជាម្ចាស់រោងចក្រថ្មី។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវ ឆ្លើយតបទៅម្ចាស់រោងចក្រវិញក្នុងរយៈពេល ០៤ (បួន) ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**មាត្រា១៤.-ថ្មី**

ក្នុងករណីដែលម្ចាស់រោងចក្រទទួលមរណភាព ឬអសមត្ថភាពតាមផ្លូវច្បាប់ អ្នកដែលទទួលសិទ្ធិគ្រប់គ្រងបន្តស្របច្បាប់ ត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ៩៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណភាព ឬបាត់បង់សមត្ថភាពតាមផ្លូវច្បាប់ ។

អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត អាចដំណើរការរោងចក្រជាបណ្តោះអាសន្នបានរហូតមានការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា១៥.-ថ្មី**

ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ១ (មួយ) ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។

ក្រៅពីករណីប្រធានសក្តិ ការផ្អាកដំណើរការរោងចក្រជាប់ៗគ្នាក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ត្រូវចាត់ទុកថាជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។ ក្នុងករណីនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចេញប្រកាសលុបប្រកាសអនុញ្ញាតបង្កើតរោងចក្រ ។

**មាត្រា១៦.-**

ម្ចាស់រោងចក្រត្រូវដាក់តាំងបង្ហាញ ប្រកាសបង្កើតរោងចក្រ លិខិតអនុញ្ញាតទាំងឡាយជាចំហានៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ ។

**មាត្រា១៧.-ថ្មី**

ក្នុងករណីដែលប្រកាសបង្កើតរោងចក្រ ឬ/និងលិខិតអនុញ្ញាតទាំងឡាយ ត្រូវបានបាត់បង់ ដោយប្រការណាមួយ ម្ចាស់រោងចក្រត្រូវធ្វើពាក្យសុំប្រកាស ឬលិខិតជំនួសមួយទៀតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ) ថ្ងៃគិតពីថ្ងៃដែលបានបាត់បង់ ។

**មាត្រា១៨.-ថ្មី**

រោងចក្រនីមួយៗ ត្រូវមានឈ្មោះរោងចក្រ ហើយផ្លាកឈ្មោះត្រូវសរសេរជាអក្សរខ្មែរ មានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត ។ ម្ចាស់រោងចក្រត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ការផ្លាស់ប្តូរឈ្មោះរោងចក្រត្រូវតែមានការយល់ព្រមពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា១៩.-ថ្មី**

ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ចាំបាច់នានាតាមការកំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា២០.-ថ្មី**

ម្ចាស់រោងចក្រដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវធ្វើការចុះបញ្ជីរោងចក្រនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៩ ថ្មី ។

**មាត្រា២១.-ថ្មី**

ទិន្នន័យ និងរបាយការណ៍ ដែលរោងចក្រផ្តល់ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺជាការសម្ងាត់វិជ្ជាជីវៈរបស់រោងចក្រ ។ ទិន្នន័យ និងរបាយការណ៍ទាំងនេះមិនត្រូវបានយកទៅផ្សព្វផ្សាយជាសាធារណៈឡើយ បើគ្មានការយល់ព្រមពីម្ចាស់រោងចក្រ ។

**មាត្រា២២.-ថ្មី**

ម្ចាស់រោងចក្រ ដែលស្ថិតនៅក្រោមច្បាប់នេះ មានកាតព្វកិច្ចបង់ប្រាក់កម្រៃសេវាកម្ម ស្របតាមការកំណត់នៃប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## សិប្បកម្ម

**មាត្រា២៣.-ថ្មី**

សិប្បកម្មត្រូវបានអនុញ្ញាតឲ្យបង្កើត និងដំណើរការ ដោយម្ចាស់សិប្បកម្មត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដែលខ្លួនបោះទីតាំងក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ) ថ្ងៃ ក្រោយថ្ងៃដំណើរការ លើកលែងតែប្រភេទសិប្បកម្មដែលមានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម មុនដំណើរការ ។

បែបបទនៃការបង្កើតនិងកិច្ចដំណើរការសិប្បកម្ម និងបទបញ្ញាត្តិពាក់ព័ន្ធផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

# ជំពូកទី ៣
# សុវត្ថិភាពឧស្សាហកម្ម

## មាត្រា២៤.-ថ្មី

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេសដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

ជនណាដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្របានឡើយ ។

## មាត្រា២៥.-

គ្រប់ផ្នែកក្នុងរោងចក្រត្រូវធានា និងរក្សាឲ្យមានពន្លឺគ្រប់គ្រាន់ និងខ្យល់ចេញចូលបរិបូរណ៍ ត្រូវធានាបាននូវភាពគ្មានគ្រោះថ្នាក់ដែលជាអាទិ៍បណ្តាលមកពី វិទ្យុសកម្ម សំឡេង ញ័រ ពន្លឺ កាំរស្មី ក្លិន ចំហាយ កំដៅ ផ្សែង ធូលី និងភាពកខ្វក់ផ្សេងៗទៀត ។

## មាត្រា២៦.-

រោងចក្រត្រូវតែមានប្រព័ន្ធបង្ការអគ្គីភ័យ ដែលរួមមានៈ

១- ប្រព័ន្ធប្រកាសភាពអាសន្ន និង មធ្យោបាយសម្រាប់ពន្លត់អគ្គីភ័យ

២- សញ្ញាប្រយ័ត្នអគ្គីភ័យ នៅកន្លែងដែលចាំបាច់

៣- ទ្វារសង្គ្រោះយ៉ាងតិចបំផុតមានចំនួនពីរ នៅតាមជាន់នីមួយៗ

៤- ផ្លូវសង្គ្រោះ សម្រាប់រថយន្តពន្លត់អគ្គីភ័យ

៥- មធ្យោបាយរំដោះខ្លួនផ្សេងៗទៀត

៦- ប្លង់បំព្រួញប្រាប់ជម្លៀសខ្លួនពេលមានអាសន្ន ។

## មាត្រា២៧.-

ម៉ាស៊ីន ឬផ្នែកនៃម៉ាស៊ីន ដែលអាចបង្កឲ្យមានគ្រោះថ្នាក់ជាយថាហេតុ ត្រូវមានគម្រប ឬឧបករណ៍ការពារ ។ ផ្នែកនៃរោងចក្រ ដែលមានគ្រោះថ្នាក់ខ្លាំងត្រូវធ្វើរបាំងព័ទ្ធជុំវិញ ។

## មាត្រា២៨.-

ត្រូវមានសញ្ញាបង្ហាញប្រាប់គ្រោះថ្នាក់ ឬបំរាមនៅកន្លែងដែលមានគ្រោះថ្នាក់ ។

**មាត្រា២៩.-**

ការប្រើប្រាស់ជាតិផ្ទុះ គ្រឿងឆេះ ជាតិពុល គឺមីគ្រោះថ្នាក់ ឬឧស្ម័ន ក្នុងផលិតកម្ម ត្រូវប្រតិបត្តិទៅតាមលក្ខណៈបច្ចេកទេស ដែលធានាបាននូវសុវត្ថិភាព ។

**មាត្រា៣០.-ថ្មី**

ឡចំហាយ ប្រព័ន្ធប្រើប្រាស់ចំហាយឧបករណ៍ ឬធុងដែលប្រើសម្ពាធខ្ពស់ ត្រូវមានការត្រួតពិនិត្យពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម មុននឹងអនុញ្ញាតឲ្យដំណើរការ។ នៅពេលដំណើរការ ការត្រួតពិនិត្យឧបករណ៍ខាងលើនេះ ត្រូវធ្វើឡើងតាមដំណាក់កាលដែលកំណត់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា៣១.-**

សំណល់ឧស្សាហកម្មគ្រប់ប្រភេទ មុននឹងបញ្ចេញចោល ត្រូវឆ្លើយទៅនឹងកម្រិតបទដ្ឋាននៃការបញ្ចេញសំណល់ ឬសារធាតុបំពុល ដែលលកំណត់ដោយបទប្បញ្ញត្តិរបស់ស្ថាប័នមានសមត្ថកិច្ច ។

ហាមដាច់ខាតចំពោះការបញ្ចេញចោលសំណល់ឧស្សាហកម្ម ដែលមានជាតិពុល ឬសារធាតុបំពុល ដែលនាំឲ្យកខ្វក់ ឬប៉ះពាល់ដល់បរិស្ថាន ដោយមិនបានឆ្លងប្រព្រឹត្តកម្មជាមុន ។

ចំពោះសំណល់ឧស្សាហកម្ម ដែលត្រូវយកមកប្រើប្រាស់ឡើងវិញ ត្រូវរក្សាទុកឲ្យបានគត់មត់តាមយថាប្រភេទ និងលក្ខណៈបច្ចេកទេស ។

**មាត្រា៣២.-**

សំណល់ឧស្សាហកម្មគ្រប់ប្រភេទ ដែលមិនអាចធ្វើប្រព្រឹត្តកម្មបាន ឬដែលបានឆ្លងកាត់ប្រព្រឹត្តកម្មរួចហើយ តែនៅមានជាតិពុល ឬមានសារធាតុបំពុលដែលនាំឲ្យកខ្វក់ ឬប៉ះពាល់ដល់បរិស្ថាន ឬមានសារធាតុវិទ្យុសកម្ម មុននឹងបញ្ចេញចោល ឬដឹកជញ្ជូនយកទៅកន្លែងផ្សេងដទៃទៀតដើម្បីរក្សាទុក ឬដើម្បីគោលបំណងណាមួយផ្សេង ត្រូវមានការត្រួតពិនិត្យ និងមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៣៣.-**

ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការបញ្ចេញចោល ការសម្អាត និងការទុកដាក់សំណល់ឧស្សាហកម្ម គ្រប់ប្រភេទរបស់រោងចក្រ ។

## មាត្រា៣៤.-ថ្មី

ក្នុងការអនុវត្តច្បាប់នេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្តិ ឬស្នើទៅរាជរដ្ឋាភិបាលបង្កើតជាអនុក្រឹត្យ ដើម្បីគ្រប់គ្រងរោងចក្រ ។

# ជំពូកទី ៤
# ការទ្រទ្រង់ និងការលើកទឹកចិត្ត

## មាត្រា៣៥.-

ការទ្រទ្រង់ និងការលើកទឹកចិត្តដើម្បីអភិវឌ្ឍរោងចក្រធុនធំ ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា៣៦.-

ចំពោះរោងចក្រធុនមធ្យម តូច និងសិប្បកម្ម ត្រូវបានអនុញ្ញាតឲ្យមានការទ្រទ្រង់ និងលើកទឹកចិត្តដោយរាជរដ្ឋាភិបាល ។ ប្រភេទ ទំហំ និងរូបភាពនៃការទ្រទ្រង់ និងការលើកទឹកចិត្តត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៥
# ការត្រួតពិនិត្យ និងអធិការកិច្ចរោងចក្រ

## មាត្រា៣៧.-ថ្មី

មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មមានសិទ្ធិចូលទៅក្នុងរោងចក្រ និងសិប្បកម្ម គ្រប់ម៉ោងធ្វើការរបស់រោងចក្រតាមកាលកំណត់ ឬមិនតាមកាលកំណត់ ដើម្បីត្រួតពិនិត្យគុណភាព ស្ថានភាព រោងចក្រ ម៉ាស៊ីន មធ្យោបាយនានា ឬសកម្មភាពផ្សេងៗទៀត ដែលម្ចាស់រោងចក្ររំលោភទៅលើបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើអធិការកិច្ចរោងចក្រដោយ៖

១-យកផលិតផលក្នុងបរិមាណសមស្រប ដើម្បីធ្វើការវិភាគអំពីគុណភាព រួមជាមួយនឹងឯកសារពាក់ព័ន្ធ ។

២-ធ្វើការស្រាវជ្រាវ បញ្ឈប់ ឬឃាត់ទុកនូវផលិតផល សម្ភារៈ វត្ថុធាតុដើមនិងឯកសារពាក់ព័ន្ធនានា ដែលអាចបណ្តាលឲ្យមានអន្តរាយដល់មនុស្ស ឬដល់ទ្រព្យសម្បត្តិក្នុងរោងចក្រ ឬទីជិតខាងរោងចក្របាន ។

៣-សាកសួរ ឬកោះអញ្ជើញម្ចាស់រោងចក្រ អ្នកគ្រប់គ្រងរោងចក្រ និយោជិត ឬកម្មករក្នុងរោងចក្រ មកបំភ្លឺព័ត៌មាន ឬសុំឲ្យផ្តល់ព័ត៌មាន និងឯកសារ ។

## មាត្រា៣៨.-ថ្មី

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិផ្អាកសកម្មភាពរោងចក្រទាំងឡាយណាដែលបានបង្កើតដោយគ្មានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាបណ្តោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីតម្រូវឲ្យម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវកំហុសរបស់ខ្លួនឡើងវិញ ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវ និងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចេញប្រកាសអនុញ្ញាតឲ្យបង្កើតរោងចក្រ ។

ប្រសិនបើមានការកែតម្រូវមិនបានអនុវត្ត ឬអនុវត្តមិនត្រឹមត្រូវ ឬមិនទាន់តាមកាលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ជាផ្អាកដំណើរការផលិតកម្ម ឬប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈនៅពីមុខរោងចក្រ ឬចុះផ្សាយតាមសារព័ត៌មាន ។

## មាត្រា៣៩.-ថ្មី

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិចេញបញ្ជាឲ្យម្ចាស់រោងចក្រឬអ្នកគ្រប់គ្រងរោងចក្រផ្អាកដំណើរការផលិតកម្មទាំងមូល ឬតាមផ្នែកនៃរោងចក្រជាបណ្តោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីឲ្យម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវ ឬកែលម្អឲ្យបានប្រសើរឡើងវិញក្នុងករណីៈ

-មានកំហុសធ្ងន់ធ្ងរផ្នែកបច្ចេកទេស ដូចមានចែងក្នុងមាត្រា ២៤ ថ្មី

-កិច្ចដំណើរការផលិតកម្ម ខុសពីការអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-កិច្ចដំណើរការផលិតកម្ម ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬអន្តរាយដល់ទ្រព្យសម្បត្តិ នៅក្នុងរោងចក្រ ឬក្រៅរោងចក្រ

-ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ មានចេតនាមិនគោរពតាមលិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវនិងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចេញបញ្ជាអនុញ្ញាតឲ្យរោងចក្របន្តដំណើរការផលិតកម្មឡើងវិញ ។

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬអនុវត្តមិនទាន់កាលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានអំណាចចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ឈប់ផ្អាកដំណើរការផលិតផល ឬប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈ នៅពីមុខរោងចក្រ ឬចុះផ្សាយតាមសារព័ត៌មាន ។

## មាត្រា៤០.-ថ្មី

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិបញ្ជូនលិខិតបញ្ជាទៅកាន់គេហដ្ឋាន ឬរោងចក្ររបស់ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ ដែលត្រូវទទួលលិខិតបញ្ជានេះ ដោយផ្ទាល់ ឬតាមសំបុត្រអនុសិដ្ឋដោយមានចុះហត្ថលេខាបានទទួល ។

ក្នុងករណីដែលម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រនោះ បដិសេធមិនព្រមទទួលលិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិអញ្ជើញអាជ្ញាធរ ឬភ្នាក់ងារនគរបាលឲ្យចូលរួមជាមួយខ្លួនដើម្បីធ្វើជាសាក្សី ។ បើម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ មិនស្ថិតក្នុងគេហដ្ឋាន ឬក្នុងរោងចក្រនោះ លិខិតបញ្ជាអាចត្រូវបានប្រគល់ទៅឲ្យជនណាម្នាក់ ដែលមានការពាក់ព័ន្ធតាមផ្លូវច្បាប់ជាមួយនឹងម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ ។

ប្រសិនបើលិខិតបញ្ជានៅតែគ្មានអ្នកទទួលជំនួស ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបិទលិខិតបញ្ជានោះនៅច្រកចូល ឬមាត់ទ្វាររោងចក្រ ឬនៅគេហដ្ឋានរបស់ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រនោះ ដោយមានវត្តមានរបស់អាជ្ញាធរ ឬភ្នាក់ងារនគរបាលជាសាក្សី ។

ក្រោយពីប្រតិបត្តិដូចបានចែងក្នុងវាក្យខណ្ឌខាងលើ លិខិតបញ្ជាត្រូវបានចាត់ទុកថាបានទទួលដោយម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ ។

## មាត្រា៤១.-ថ្មី

ក្នុងករណីដែលមានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់នៅក្នុងរោងចក្រ ដែលបណ្ដាលឲ្យរោងចក្រត្រូវផ្អាកដំណើរការទាំងស្រុងលើសពី៧ (ប្រាំពីរ)ថ្ងៃ ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុនោះ ។

ពេលដែលមានឧប្បត្តិហេតុ ឬ គ្រោះថ្នាក់កើតឡើងដូចខាងលើ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវធ្វើអធិការកិច្ចរោងចក្រហើយអនុវត្តតាមមាត្រា ៣៧ ថ្មី ឬមាត្រា ៣៩ ថ្មី វាក្យខណ្ឌទី ១ ប្រសិនបើចាំបាច់ ។

## មាត្រា៤២.-ថ្មី

ក្នុងការចុះធ្វើអធិការកិច្ច មន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបង្ហាញប័ណ្ណសម្គាល់ខ្លួន និងលិខិតបញ្ជាបេសកកម្មជូនទៅម្ចាស់រោងចក្រ ឬជនដែលខ្លួនត្រូវទំនាក់ទំនង ។

ការធ្វើអធិការកិច្ចរោងចក្រ ត្រូវមានកំណត់ហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

# ជំពូកទី ៦
# ទោសប្បញ្ញត្តិ

## មាត្រា៤៣.-ថ្មី

ម្ចាស់សិប្បកម្មណា ដែលពុំបានធ្វើការជូនដំណឹងជាលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដែលខ្លួនបានបោះទីតាំង ដូចកំណត់ក្នុងមាត្រា ២៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០ ០០០រៀល (ប្រាំរយពាន់រៀល) ទៅ ២ ៥០០ ០០០រៀល (ពីរលានប្រាំរយពាន់រៀល) ។

ជនណាបង្កើតប្រភេទសិប្បកម្ម ដែលមានចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដូចក្នុងមាត្រា ២៣ ថ្មី ដោយគ្មានការអនុញ្ញាតឬល្មើសនឹងមាត្រា ២៣ ថ្មី ឬបទប្បញ្ញត្តិដទៃទៀតពាក់ព័ន្ធនឹងមាត្រា ២៣ ថ្មី វាក្យខ័ណ្ឌទី ២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០រៀល (មួយលានរៀល) ទៅ ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ។

## មាត្រា៤៤.-

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១១ ថ្មី មាត្រា ១៣ ថ្មី មាត្រា ១៤ ថ្មី មាត្រា ១៥ ថ្មី វាក្យខ័ណ្ឌទី ១ មាត្រា ១៦ មាត្រ ១៨ ថ្មី មាត្រ ៤១ ថ្មី វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ រៀល (ពីរលានរៀល) ទៅ ១០ ០០០ ០០០ រៀល (ដប់លានរៀល) ។

## មាត្រា៤៥.-ថ្មី

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៤ ថ្មី នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០រៀល (ប្រាំលានរៀល) ទៅ ២៥ ០០០ ០០០រៀល (ម្ភៃប្រាំលានរៀល)។

ប្រសិនបើមានគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រព្រឹត្តល្មើសនឹងមាត្រាខាងលើ ម្ចាស់រោងចក្រត្រូវទទួលសំណងខូចខាតទាំងអស់ដល់ជនរងគ្រោះ ។ ក្នុងករណីនេះ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់។

## មាត្រា៤៦.-ថ្មី

ម្ចាស់រោងចក្រណា ដែលប្រព្រឹត្តិល្មើសនឹងមាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ មាត្រា ២៩ មាត្រា ៣០ ថ្មី នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ រៀល (ពីរលានរៀល) ទៅ ១០ ០០០ ០០០ រៀល (ដប់លានរៀល) ។

ក្នុងករណីបទល្មើសនេះបង្កឲ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬអន្តរាយដល់ទ្រព្យសម្បត្តិក្នុង ឬក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមព្យសនកម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា៤៧.-**

ជនណាដែលមិនផ្តល់របាយការណ៍ ឬផ្តល់របាយការណ៍មិនពិត ឬប្រព្រឹត្តល្មើសនឹងមាត្រា ១៩ ថ្មី នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១០ ០០០ ០០០ រៀល (ដប់លានរៀល) ទៅ ៥០ ០០០ ០០០ រៀល (ហាសិបលានរៀល) នឹងផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា៤៨.-**

ជនណាដែលដំណើរការរោងចក្រ ដោយប្រព្រឹត្តល្មើសនឹងមាត្រា ៣៨ ថ្មីវាក្យខ័ណ្ឌទី១ និងមាត្រា ៣៩ ថ្មី វាក្យខ័ណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០ ០០០ ០០០ រៀល (ម្ភៃលានរៀល) ទៅ ១០០ ០០០ ០០០ រៀល (មួយរយលានរៀល) ឬ/និងទោសដាក់ពន្ធនាគារ ពី ៦ ខែ ទៅ ១ ឆ្នាំ ។

**មាត្រា៤៩.-ថ្មី**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤ ថ្មី មាត្រា ៩ ថ្មី និងមាត្រា ២០ ថ្មី នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ រៀល (ដប់លានរៀល) ទៅ ៥០ ០០០ ០០០ រៀល (ហាសិបលានរៀល) ។

ក្នុងករណីបទល្មើសនេះបណ្តាលឲ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬអន្តរាយទ្រព្យសម្បត្តិក្នុង ឬក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមព្យសនកម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា៥០.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១០ និងមាត្រា ២៥ នៃច្បាប់នេះ ត្រូវទទួលទោស និងសំណងតាមច្បាប់ស្តីពីការងារ ។

**មាត្រា៥១.-**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣១ មាត្រា ៣២ និងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវទទួលទោស និងសំណងតាមច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៥២.-**

មន្ត្រីមានសមត្ថកិច្ចណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៨ ថ្មី វាក្យខ័ណ្ឌទី ១ និងមាត្រា ២១ ថ្មី នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល តាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬ ផ្ដន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ រៀល (ពីរលានរៀល) ទៅ ១០ ០០០ ០០០ រៀល (ដប់លានរៀល) និងផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ១ ឆ្នាំ ឬ ទោសណាមួយ ។

**មាត្រា៥៣.-**

ជនណាដែលរារាំង ប្រឆាំងនឹងការអនុវត្តច្បាប់នេះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ចំនួនពី ២ ០០០ ០០០ រៀល (ពីរលានរៀល) ទៅ ១០ ០០០ ០០០ រៀល (ដប់លានរៀល) និងផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៦ ខែ ។

**មាត្រា៥៤.-**

ចំពោះជនណាដែលបានប្រព្រឹត្តល្មើសហើយពុំរាងចាល ត្រូវផ្ដន្ទាទោសទ្វេជាពីរ តាមបទល្មើសនៃមាត្រានីមួយៗក្នុងជំពូកនេះ ។

**មាត្រា៥៥.-ថ្មី**

ទោសទណ្ឌទាំងឡាយណាដែលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥០០ ០០០ រៀល (ប្រាំរយពាន់រៀល) ទៅ ១០ ០០០ ០០០រៀល (ដប់លានរៀល) មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិពិន័យអន្តរការណ៍។

ក្នុងករណីរឹងរូស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា៥៦.-ថ្មី**

ក្រោយពីច្បាប់នេះចូលជាធរមាន រោងចក្រ សិប្បកម្មទាំងអស់ដែលបានបង្កើតរួចហើយ និងមិនទាន់មានប្រកាសបង្កើតរោងចក្រ ឬលិខិតអនុញ្ញាត ឬមិនទាន់បានចុះបញ្ជីត្រូវមកបំពេញសំណុំបែបបទឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដែលសិប្បកម្មបោះទីតាំងក្នុងរយៈពេល៦ (ប្រាំមួយ)ខែ យ៉ាងយូរ ។ ក្នុងករណីចាំបាច់រយៈពេលនេះអាចបន្តបាន៣ (បី) ខែបន្ថែម ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា៥៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ឧបសម្ព័ន្ធ**

## ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

ព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤

ពរល.១៤១០.១៣០៥ **ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

**និង**

## ច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនាឆ្នាំ២០០៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦

ពរល.០៦០៦.២៩២

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

# CHAPTER I

# General Provision

**Article 1: NEW**

This law governs all factories and Handicrafts throughout Kingdom of Cambodia which are under the leading and administering authority of the Ministry of Industry and Handicraft without affecting authorities of other concerned ministries and institutions.

**Article 2:**

Factories and Handicrafts in this law mean buildings, places or vehicles for producing and transforming raw material or semi-final product to a new product or/and for performing other activities such as assembling, repairing, testing, packaging, filling, maintenance, storage or improvement to satisfy the market demand.

**Article 3:NEW**

Factories and Handicrafts, which are under the leading and administering authority of the Ministry of Industry and Handicraft, are as follows:

1. Food, beverage and tobacco
2. Textile, wearing apparel and leather product
3. Paper product
4. Chemical, rubber and plastic product, except oil and gas industry
5. Non-metallic mineral based product
6. Basic metal
7. Fabricated metal, machinery and equipment
8. Other sectors such as: Production of jewelry, decoration material, music instrument, sport equipment, toy and office equipment.

# CHAPTER II

# Establishment and Operation

## Part I

## FACTORY

**Article 4:NEW**

The establishment of factory, as specified in article 3, shall have permit from the Ministry of Industry and Handicraft which the approval of the concerned institutions. The establishment of factory is targeting on :

- Preparation of location or/and the construction of building for the factory operation.
- Construction of building for installation of machinery for the factory operation.
- Machinery installation in building, place or vehicle for the factory operation.
- Raw material for factory operation.

**Article 5:**

The factory owner shall be governed by this law and may be physical or legal entity. The factory owner can manage the factory by him/herself or authorize other to manage the factory on his/her behalf. But in any case, the factory owner shall be legally liable for all activities of the factory and its products quality to consumers.

**Article 6:**

Quality control, standard determination, registration and standard mark of product shall comply with the existing laws.

**Article 7:NEW**

The Ministry of Industry and Handicraft shall provide any certificates concerning the production in according with the application of the factory owner if it deems to be necessary.

**Article 8:NEW**

The Ministry of Industry and Handicraft shall reply with its decision to the applicant for the factory establishment within a maximum period of 7 (seven) working days from the date of the receipt of the complete and correct application.

In case of rejection of the application, the Ministry of Industry and Handicraft shall explain clearly the reasons of its decision.

**Article 9:NEW**

Before starting the operation of the factory, the factory owner shall inform to the Ministry of Industry and Handicraft within the minimum 15 (fifteen) days in advance.

**Article 10:**

For the establishment and operation of factory, the factory owner shall give priority to Cambodian Engineer and Technician. The conditions of recruitment of foreign engineer and technician shall comply with the existing laws.

**Article 11:NEW**

For the expansion or the establishment of branch or relocation of the factory, the permit shall be obtained from the Ministry of Industry and Handicraft.

### Article 12:

The expansion of factory means a 20 (twenty) % increased of the original capacity by :

1. The increase of number machineries or the change of machineries
2. The modification for preparation or expansion or construction building.
3. The change of product item or the addition of the product item.
4. The expansion of the factory space.

The establishment of branch means the establishment of new production base which produce the product to support the mother factory.

The relocation is the change of the old to new location of the factory.

### Article 13:NEW

In case of change of factory owner, the new owner shall apply for recognition as the factory owner to the Ministry of Industry and Handicraft within a maximum period of 10 (ten) working days from the date when he get the right to be the new factory owner. The Ministry of Industry and Handicraft shall reply to the factory owner within a maximum period of 4 (four) working days from the date of receipt of the application.

### Article 14:NEW

In case of death or legal disability of the factory owner, the legal successor shall apply for recognition as the factory owner to the Ministry of Industry and Handicraft within a maximum period of 45 (fortify five) working days from the date of death or legal disability.

The successor may temporarily operate factory until there is the recognition as the factory owner from the Ministry of Industry and Handicraft.

### Article 15:NEW

The factory owner shall inform to the Ministry of Industry and Handicraft in writing within the minimum period of 1 (one) month prior to the date of the permanent cease of the operation.

Beside the case of force majeure, the continuous cease of operation within the period of 12 (twelve) months shall be deemed as permanent cease of factory operation. In this case, the Ministry of Industry and Handicraft shall invalidate the establishment permit.

### Article 16:

The factory owner shall present the establishment permit and other permits at an appropriate open place in his/her factory, where it is easy to visual view.

### Article 17:NEW

In the case that the establishment permit and other permits have been lost by certain reasons, the factory owner shall apply for another permit or replacement letter from the Ministry of Industry and

Handicraft within maximum period of 15 (fifteen) days from the date of loss.

**Article 18:NEW**

Each factory shall have name and signboard shall be written in Khmer while it shall be bigger than and on the top of other languages. The factory owner shall install his/her factory signboard in front of factory, where it is easy to visual view.

Changing the name of factory shall be approved by the Ministry of Industry and Handicraft.

**Article 19:NEW**

The factory owner shall provide accurate data and necessary report in accordance with the determination of the Ministry of Industry and Handicraft.

**Article 20:NEW**

The factory owner, who is not under the authority of the Ministry of Industry and Handicraft, shall have factory registration at the Ministry of Industry and Handicraft, and provide data and report as prescribed in article 19.

**Article 21:NEW**

Data and reports, provided by the factory to the Ministry of Industry and Handicraft, are professional secrets of the factory. These data and reports shall not be publicly released unless there is permission from the factory owner.

**Article 22:NEW**

The factory owner, who is under this law, shall be obliged to pay service fee specified by the joint announcement between the Ministry of Industry and Handicraft and the Ministry of Economic and Finance.

## Part II

## HANDICRAFT

**Article 23:NEW**

The handicraft is permitted to establish and operate as long as the handicraft owner inform the local authority and register at the Provincial/Municipal Department of Industry and Handicraft where his/her enterprise is located within period of 7 (seven) days following the operation date, except the kind of handicraft specified by the announcement of the Ministry of Industry and Handicraft, which shall be applied for permit from the Ministry of Industry and Handicraft prior to the operation.

The formality of the establishment and operation of handicraft and other concerned provisions shall be specified by the announcement of the Ministry of Industry and Handicraft.

# CHAPTER III

# Industrial Safety

**Article 24:NEW**

The set-up of all areas in the factory shall comply with the technical conditions set by the announcement of the Ministry of Industry and Handicraft.

No person without technical skill shall be hired or assigned to set up the factory.

**Article 25:**

All areas in the factory shall be ensured and maintained with appropriate light and enough ventilation, shall be ensured that it is free of accident primarily caused by radio activity, noise, vibration, light, ray, smell, steam, heat, smoke, dust and other pollutants.

**Article 26:**

Factory shall have fire-extinguishing system which includes :

1. Fire alarm system and fire extinguisher utilities
2. "Fire Caution" sign at necessary places
3. At least two emergency exits at each floor
4. Rescue ways for fire fighting trucks
5. Other escape means
6. Compact plan for evacuation in emergency

**Article 27:**

Machineries and part of machineries, which may eventually cause accident, shall have covers or protecting equipment. Area of factory, which may cause serious accident, shall be surrounded by fence.

**Article 28:**

"Accident Caution" signs or "Prohibition" signs shall be placed at location where accident may occur.

**Article 29:**

The use of explosive, flammable material, poison, dangerous chemical or gas in the production shall comply with the technical conditions that ensure safety.

**Article 30:NEW**

Steam boilers, steaming systems, equipment or tanks with high pressure shall be controlled by the Ministry of Industry and Handicraft before being allowed to operate. During the operation, the control of above-mentioned equipment shall be done in place specified by the Ministry of Industry and Handicraft.

**Article 31:**

Before being dumped, all kinds of industrial wastes shall be complied with standard for discharge of waste and hazardous substances set by the regulation of component of institutions.

It is strictly prohibited to discharge toxic industrial waste or hazardous substances polluting environment without coming across treatment.

Industrial waste, which is to be reduced, shall be thoroughly stored with specifications and technical conditions.

**Article 32:**

All kinds of industrial waste, which cannot be treated, or have been treated but are still toxic substances causing pollution or affecting environment or consist of radioactive substance shall be controlled and permitted by competed institutions before being discharged or transported to other place for storage or other purposes.

**Article 33:**

Factory owner shall be liable for the discharge, cleaning and storage of all kinds of industrial waste of the factory.

**Article 34:NEW**

Within the enforcement of this law, the Ministry of Industry and Handicraft has the authority to issue the regulations or request the Royal Government to issue sub-decree to administer the factory.

## CHAPTER IV

## Support and Incentives

**Article 35:**

Supports and incentives for the development of large size factory shall be implemented in accordance with the law on investment of the Kingdom of Cambodia.

**Article 36:**

For medium and small factories and handicrafts, supports and incentives are approved by the Royal incentives shall be Government. Types, sizes and forms of the supports and specified by sub-decree.

# CHAPTER V

## Control and Inspection of Factory

**Article 37:NEW**

Competent officials of the Ministry of Industry and Handicraft are eligible to enter the factory anytime in the working hours in accordance with a specified or a non-specified date to control the quality, factory situation, machinery, other means or activity where the factory owner violates the provisions of this law. In necessary case, the inspection of the factory is carried out by :

1. Taking the product sample with an appropriate quantity for quality analysis together with other concerned document.
2. Investigating, halting or restraining the product, material, raw-material and concerned document which may cause accident to human or asset of the factory or the surrounding area.
3. Questioning or summoning factory owner, manager, employee or worker in the factory to clarify information or to request for information and document.

**Article 38:NEW**

The Ministry of Industry and Handicraft has the authority to temporarily cease the activity of any factory established without permit from the Ministry of Industry and Handicraft for a specified period to order the factory owner or manager to adjust the mistake.

If the adjustment is proper and completed on time, the Ministry of Industry and Handicraft shall issue the permit to the factory.

If the adjustment has not been carried out or is not proper or not on time, the Ministry of Industry and Handicraft has the authority to issue the announcement of permanent closure of the factory.

The order of temporary cease of the production or the announcement of permanent closure of the factory shall be publicly presented in front of the factory or released in the press.

**Article 39:NEW**

The Ministry of Industry and Handicraft has the authority to order the factory owner or manager to temporarily cease the entire production or certain sections of the factory for a specified period so as the factory owner or manager makes adjustment or improvement in the case:

- Serious technical mistake as prescribed in article 24
- The production process which does not comply with the permit of the Ministry of Industry and Handicraft.
- The production which may cause accident to human or destruction of assets inside or outside the factory.
- The factory owner or manager intentionally disrespect the order letter of the Ministry of Industry and Handicraft.

If the adjustment is proper and completed on time, the Ministry of Industry and Handicraft shall permit the factory to restart the production.

If the adjustment have not been carried out or is not proper or not on time, the Ministry of Industr and Handicraft has the power to issue the announcement of the final closure of the factory.

The order of temporary cease of the production or the the announcement of permanent closure of the factory shall be publicly presented in front of the factory or released in the press.

**Article 40:NEW**

The Ministry of Industry and Handicraft has the authority to send the order letter to the residence or the factory of the factory owner or manager who shall directly receive this letter or by registered letter with the signature for receipt.

In case that factory owner or manager refuse to accept the order letter of the Ministry of Industry and Handicraft, the Ministry has the authority to invite the authorities or police officers as witness to accompany with it. If the factory owner or manager is not in the residence or in the factory, the order letter can be given to any person who is legally related to the factory owner or manager.

If there is no person receiving the order letter on behalf of the owner or manager, the Ministry of Industry and Handicraft shall stick that letter at the entrance or the gate or at the residence of the factory owner or manager with the presence of the authorities or police officers as witness.

After what prescribed in the above paragraph are executed, the order letter is deemed to be received by the factory owner or manager.

**Article 41:NEW**

In case that, there is any incident or accident in the factory which leads to the complete cease of operation for more than 7 (seven) days, the factory owner or manager shall inform in writing to the Ministry of Industry and Handicraft within the maximum period of 10 (ten) days following the date of that occurrence.

At the time when the above incident or accident occurs, the Ministry of Industry and Handicraft shall inspect the factory and enforce article 37 or 39, paragraph 1 if necessary.

**Article 42:NEW**

Officers of the Ministry of Industry and Handicraft shall present identification card and the letter of mission to the factory owner or the contact person during the inspection.

The inspection of the factory shall have proper and clear minute.

# CHAPTER VI

## Penalties

### Article 43:NEW

Any handicraft owner, who has not informed the local authority in writing, and not registered at the municipal or provincial department of Industry and Handicraft where his/her enterprises are located, as specified in article 23 paragraph 1, shall be subject to fine penalty from 500,000 (five hundred thousand) Riels to 2,500,000 (two million five hundred thousand) Riels.

Any person who establishes handicraft, specified by the announcement of the Ministry of Industry and Handicraft as prescribed relating article 23 without permission or violates article 23 or other provisions relating article 23 paragraph 2 of this law, shall be subject to fine penalty from 1,000,000 (one million) Riels to 5,000,000 (five million) Riels.

### Article 44:

Any factory owner, who violates article 11, 13, 14, 15 paragraph 1, article 16, 17, 18, 41 paragraph 1, shall be subject to fine penalty from 2,000,000 (two million) Riels to 10,000,000 (ten million) Riels.

### Article 45:NEW

Any factory owner, who violates article 24, shall be subject to fine penalty from 5,000,000 (five million) Riels to 25,000,000 (twenty five million) Riels.

If there is the accident caused by violation of the above article, the factory owner shall compensate all the damages to the victims. In this case, the competent officials of the Ministry of Industry and Handicraft shall refer the case to the court for judgment in accordance with the existing laws.

### Article 46:NEW

Any factory owner, who violates article 26, 27, 28, 29, 30 shall be subject to fine penalty from 2,000,000 (two million) Riels to 10,000,000 (ten million) Riels.

In the case that this violation causes the fatal accident to human or destruction of asset inside or outside the factory, the competent officials of the Ministry of Industry and Handicraft shall refer the case to the court for decision on the compensation of damages in accordance with the prejudgment, and on penalty in accordance with existing laws.

### Article 47:

Any person who does not provide report or provide inaccurate report or violates article 19, is subject to fine penalty from 10,000,000 (ten million) Riels to 50,000,000 (fifty million) Riels and to penalty as specified in penalty law.

**Article 48:**

Any person, who operates the factory, violate article 38 paragraph 1 and article 39 paragraph 1 of this law, shall be subject to fine penalty from 20,000, 000 (twenty million) Riels to 100,000,000 (one hundred million) Riels or to imprisonment from 6 (six) months to 1 (one) year.

In the case of violation of article 39 paragraph 3 of this law,he/she shall be subject to fine penalty from 30,000,000 (thirty million) Riels to 150,000,000 (one hundred and fifty million) Riels and to imprisonment from 1 (one) year to 3 (three) years.

**Article 49:NEW**

Any person, who violates article 4, 9, 20, shall be subject to fine penalty from 10,000,000 (ten million) Riels to 50,000,000 (fifty million) Riels.

In the case that this violation causes the fatal accident to human or destruction of asset inside or outside factory, the competent officials of the Ministry of Industry and Handicraft shall refer the case to the court for the decision on the compensation of damages in accordance with the prejudgment, and on penalty in accordance with existing laws.

**Article 50:**

Any factory owner, who violates article 10 and article 25, shall be subject to fine penalty and compensation in accordance with labor law.

**Article 51:**

Any factory owner, who violates article 31, 32, 33 of this law, shall be subject to fine penalties and compensation in accordance with the law environment protection and natural resource management.

**Article 52:**

Any competent official, who violates article 8 paragraph 1 and article 21 of this law, shall be subject to administrative punishment in accordance with law on join-articles of the civil servants or to fine penalty between 2,000,000 (two million) Riels to 10,000,000 (ten million) Riels and to imprisonment from 6 (six) months to 1 (one) year or any certain penalty.

**Article 53:**

Any person, who resists the enforcement of this law, shall be subject to fine penalty from 2,000,000 (two million) Riels to 10,000,000 (ten million) Riels, and to imprisonment from 1 (one) month to 6 (six) months.

**Article 54:**

Any person, who commits the violation and do not resolve the cease to violation, shall be subject to a double fine penalty in accordance with the violations of each article in this chapter.

**Article 55:NEW**

For any fine penalty from 500,000 (five hundred thousand) Riels to 10,000,000 (ten million) Riels, the competent officials of the Ministry of Industry and Handicraft have the authority to impose a fine.

In the case of refusal to pay this transactional fine, competent officials of Ministry of Industry and Handicraft, shall refer the case to the court.

## CHAPTER VII

## Transitional Provision

**Article 56:NEW**

Subsequent to time when this law take into effect, all factories and handicrafts which are already established without establishment certificate or permit, or not yet registered, shall complete the formality in accordance with the provisions of this law at the Ministry of Industry and Handicraft or at Municipal or Provincial Department of Industry where they are located within the maximum period of 6 (six) months.If needed, this period can be further extended for an additional period of 3 (three) months.

## CHAPTER VIII

## Final provision

**Article 57:**

All provisions contrary to this law shall be abrogated.

# AMENDMNET LAW ON ADMINISTRATION OF FACTORY AND HANDICRAFT

Phnom Penh, October 23, 2014

**King's Signature**

**NORODOM SIHAMONI**

Have submitted for the King's Signature

Prime Minister

Signature

**HUN SEN** Have informed to Prime Minister

Ministry of Industry and Handicraft

Signature

**CHAM PRASIDH**

*AND*

# LAW ON ADMINISTRATION OF FACTORY AND HANDICRAFT

Phnom Penh, June 23, 2006

**King's Signature**

**NORODOM SIHAMONI**

Have submitted for the King's Signature

Prime Minister

Signature

**HUN SEN** Have informed to Prime Minister

Ministry of Industry, Mines and Energy

Signature

**SUY SEM**